# លទ្ធិពុទ្ធរាជ

## (ទស្សនវិជ្ជានយោបាយខ្មែរ)

បណ្ឌិត **ឆ្កាន់ ធុល**
មន្ត្រីនាយកដ្ឋានទស្សនវិជ្ជានិងសង្គមវិជ្ជា
វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសង្គម
រាជបណ្ឌិត្យសភាកម្ពុជា

## ១- សេចក្តីផ្តើម

ផ្ទុយទៅនឹងលទ្ធិទេវរាជនៃព្រហ្មញ្ញសាសនាដែលព្រះបាទជ័យវរ្ម័នទី២គោរពព្រះឥស្សរបានប្រារព្ធធ្វើ ឡើងនៅលើភ្នំគូលែន គឺជាសញ្ញាណមួយ នៃការប្រកាសឯករាជ្យរបស់ខ្មែរ ហើយក៏ជាសញ្ញាណមួយទៀតនៃការចាប់ផ្តើមនិងការរីកចម្រើននៅសម័យអង្គរដែរ។ តាមលំអាននេះ ព្រះបាទជ័យវរ្ម័នទី៧ ទ្រង់មិន កាន់លទ្ធិទេវរាជគោរពព្រះឥស្សរក៏ពិតមែន ប៉ុន្តែទ្រង់បានបង្កើតលទ្ធិដ៏មានឥទ្ធិពលថ្មីមួយផ្សេងទៀតនៃពុទ្ធសាសនាមហាយាន ពោលគឺ **លទ្ធិពុទ្ធរាជ**ដើម្បីដឹកនាំហើយនិងអភិវឌ្ឍអាណាចក្ររបស់ព្រះអង្គដូច ព្រះបាទជ័យវរ្ម័ន ទី២ដែរ។ លទ្ធិពុទ្ធរាជនេះ មានកម្លាំងខ្លាំង អាចជំរុញអរិយធម៌ខ្មែរ សម័យអង្គរឱ្យឡើងដល់កំពូលបាន។ ដើម្បីបង្ហាញឱ្យឃើញពីកម្លាំងដ៏ខ្លាំងនេះ លទ្ធិពុទ្ធរាជមានដំណើរសាវតារដូចខាងក្រោម៖

## ២- សាវតារពុទ្ធរាជ

លទ្ធិពុទ្ធរាជ គឺជាមែកធាងរបស់ពុទ្ធសាសនាមហាយានដែលពុទ្ធសាសនាមហាយាននេះបាននាំចូលតាំងពីដើម ព.ស.វ. ទី១២[1] ឬចុង ស.វ.ទី៧[2] មកម្ល៉េះ។ គេបានរកឃើញសិលាចារឹក ចុះ កាលកំណត់ ៧៩១ នៅប្រាសាទ **តាគាម** ក្នុងខេត្តសៀមរាប។ គេបានចាត់ទុកសិលាចារឹកនេះថា ជាសក្ខីភាពមួយចាស់ជាងគេ នៃព្រះពុទ្ធសាសនាមហាយាន នៅស្រុកខ្មែរ ព្រោះឯកសារនេះបាននិយាយពីការកសាងបដិមាពោធិសត្វលោកេស្វរៈ ជា ពោធិសត្វដែលគេនិយមគោរពបូជាជាងគេនៅស្រុកខ្មែរ។

---

១ ប៉ាង ខាត់, ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរនៅក្នុង "*ពុទ្ធសាសនា២៥០០*", ភ្នំពេញ, ព.ស. ២៥៤៥ (គ.ស.១៩៥៧), ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ គ.ស. ២០០១, ទំព័រ ៥៨

២ ត្រឹង ងា, ប្រវត្តិសាស្ត្រខ្មែរ ភាគ១ និងភាគ២ (សម្រាប់មធ្យមសិក្សានិងឧត្តមសិក្សា)" ភ្នំពេញ, ព.ស.២៥១៧ គ.ស.១៩៧៣, ទំព័រ ១០៨

តើ **លទ្ធិពុទ្ធរាជ** គឺជាលទ្ធិដូចម្តេច? តើកើតឡើងនៅពេលណា? តើជាលទ្ធិថ្មី របស់ព្រះបាទ**ជ័យវរ្ម័នទី៧** ឬជាលទ្ធិរបស់ស្តេចមុនៗ ឬក៏ជាលទ្ធិដែលបានផ្សាយចូលមកពីខាងក្រៅ?

បើពិនិត្យមើលព្រះរាជា នៅសម័យអង្គរដែលគោរពព្រះពុទ្ធសាសនាមហាយានមុនព្រះបាទ**ជ័យវរ្ម័នទី៧** មានព្រះបាទ**សូរ្យវរ្ម័នទី ១** ព.ស១៥៤៥ (គ .ស. ១០០២-១០៥០)។ ព្រះអង្គជាបឋមក្សត្រ ពុទ្ធសាសនិកដែលបានទទួល[3] ស្គាល់ព្រះ ពុទ្ធសាសនាជាផ្លូវការក្នុងសម័យមហា នគរមិនមែនគ្រាន់តែទទួលស្គាល់នោះទេ ទ្រង់ក៏ជាព្រះរាជសាសនូបត្ថម្ភដ៏ប្រសើរទៀតផង។ ព្រះអង្គទំនងជាព្រះរាជវង្ស ខាងព្រះវរបិតាដែលមានការទាក់ទងមកពីព្រះរាជានៅក្រុង **តាំព្រលឹង្គៈ** (តាម្ពលិង្គៈ) នៅជ្រោយម៉ាឡាយូ ដែលកាលនោះនៅ ក្នុងអំណាចអាណាចក្រ **ស្រីវិជ័យ** (កោះ សុមាត្រា) ខាងព្រះវរមាតាជាប់ទាក់ទង មកពីព្រះរាជវង្ស **សប្តទេវកុល** ពីព្រះនាង **ប្រាណា** ជាអគ្គមហេសីព្រះបាទរាជេន្ទ្រ វរ្ម័នទី២ និងជាព្រះនាយិកានៃការិយាល័យរបស់ព្រះបាទជ័យវរ្ម័នទី៥ផង។ ព្រះពុទ្ធសាស នាលទ្ធិមហាយាន មានការផ្សាយឥទ្ធិពលចូលមកប្រទេសខ្មែរខ្លាំងក្នុងរាជព្រះអង្គ **គម្ពីរដីកា** ក្តី **គ្រូបាអាចារ្យ** ក្តី សុទ្ធសឹងចេញមកពី **តាំព្រលឹង្គៈ** ដែលជាមជ្ឈ មណ្ឌលផ្សាយព្រះពុទ្ធសាសនា បានជាទីឋាននេះមានសមញ្ញាថា "ស្រីធម៌រាជនគរ ក្រុងនៃស្តេចធម៌ដ៏មានសិរី" (នគរស្រីធម្ម រាជនៅភាគ ខាងក្រោមប្រទេសថៃសព្វថ្ងៃ នេះ)។ ក្នុងរជ្ជកាលព្រះអង្គរាជអាណាចក្រខ្មែរធំទូលាយណាស់ ពីព្រោះបានរួមទាំង **លពបូរី** ជា**អាណាចក្រមន សម័យទ្វារវតី** ជាដែនដីដែលមនមកពី **ថាទុង** (សុធម្មបុរៈ) និង **ប៉ែគូ** ព្រមទាំងមននៅទន្លេមេណាម និងទន្លេឥរាវឌី (ឥរាវតី?) ដែលបានកសាង **ជារាមញ្ញប្រទេស** ឡើង។ ព្រះបាទសូរ្យវរ្ម័នទី១ ជាព្រះរាជាមានប្រាជ្ញាឈ្លៀវឈ្លាស[4] ណាស់ ទ្រង់ប្រកប ដោយខន្តីធម៌យ៉ាងខ្ពង់ខ្ពស់ ទ្រង់ជាពុទ្ធ សាសនិកលទ្ធិមហាយានតែចេះរក្សាហើយប្រោសប្រាណ ព្រះពុទ្ធសាសនាថេរវាទ ព្រមទាំងសាសនាព្រាហ្មណ៍ ដោយធម៌ថែមទៀតមិនឱ្យសាសនាទាំង នេះមានមោះហ្មងនឹងគ្នាឡើយ។ សិលាចារឹកខ្មែរនៅ **លវបុរី** ពីគ.ស. ១០២២-១០ ២៥ ចែងទុកថា ភិក្ខុមហាយានក្តី ភិក្ខុថេរ វាទក្តី នៅជាមួយគ្នា សុខក្សេមក្សាន្តឯពួកតាបសីយោគី ក៏ប្រតិបត្តិតាមលទ្ធិសាសនាព្រាហ្មណ៍បានដោយសេរី មិនមានការសង្កត់សង្កិនគ្នាទៅវិញទៅមកឡើយ។ អ្នកប្រាជ្ញខាងសិល្បសាស្ត្របានឃើញថា មាន ការកើតព្រះពុទ្ធរូបប្រក់នាគដំបូងក្នុងរាជ្យ ព្រះអង្គដែលមិនធ្លាប់មានពីមុនៗ ទ្រង់ជា ក្សត្រពុទ្ធសាសនិកតែទ្រង់នៅគោរព "ទេវរាជ" តាមប្រពៃណីរាជ

[3] ប៉ាង ខាត់, ដ.ឯ.ម., ទំព័រ ៦៦

[4] ប៉ាង ខាត់, ដ.ឯ.ម., ទំព័រ ៦៧

សម្បត្តិដូច ដើម[៥]។ លុះទ្រង់ទីវង្គត់ទៅ គេថ្វាយព្រះបច្ឆាមរណនាមទ្រង់ថា "**ព្រះនិព្វានបទ**"។ នៅក្នុងរជ្ជកាលនេះ គេរកមិនឃើញមានប្រើពាក្យថា "**ពុទ្ធរាជ**" នៅក្នុងការគ្រប់គ្រងរដ្ឋនោះទេ។

តមកមានរជ្ជកាលរបស់ព្រះបាទ **ធរណីន្ទ្រវរ្ម័នទី២** ឡើងសោយរាជ្យក្នុង ព.ស. ១៦៩០ ដែលមានព្រះនាង **ស្រីជ័យរាជចូឌាមណី** ជាព្រះអគ្គហេសី ហើយដែលមានព្រះរាជបុត្រមួយព្រះអង្គ[៦] ប្រកបដោយគុណសម្បត្តិគ្រប់ប្រការ ជាមកុដរាជកុមារទៅអនាគតគឺ ព្រះបាទ **ជ័យវរ្ម័នទី៧**។ ព្រះបាទធរណីន្ទ្រវរ្ម័នទី២ ទ្រង់កាន់ព្រះពុទ្ធសាសនាមុតមាំណាស់។ សិលាចារឹក (គាថា ទី១៧) នៅប្រាសាទតាព្រហ្ម សរសើរព្រះអង្គថា "ទ្រង់ (ធរណីន្ទ្រវរ្ម័នទី២) សព្វព្រះរាជហឫទ័យខ្លាំងចំពោះ ទឹកអម្រឹតនៃសាសនាព្រះច័ន្ទ ពោលគឺ ព្រះសាក្យមុនី ទ្រង់បានប្រគល់សិទ្ធិដល់ភិក្ខុព្រាហ្មណ៍ និងប្រជាជន ព្រះអង្គដែល ចង់បាន ទ្រង់មានព្រះរាជបំណងចង់យកសារៈធម៌ពីកាយដែលមិនមានសារៈ ពោលគឺអាយតនៈជាអសុភ ហើយទ្រង់ បង្អោនព្រះវរកាយក្រាបថ្វាយបង្គំដោយគោរព ចំពោះព្រះបាទនៃព្រះជិនស្រីគ្រប់ កាលទាំងពួង។ នៅក្នុងរជ្ជកាលនេះ ក៏គេរកមិន ឃើញមានប្រើពាក្យ "**ពុទ្ធរាជ**" នេះនៅការគ្រប់គ្រងនៅឡើយដែរ បើទោះជាព្រះបាទ **ធរណីន្ទ្រវរ្ម័នទី២** ទ្រង់កាន់ពុទ្ធសាសនា មហាយានដ៏រឹងមាំក៏ដោយ។

តពីរជ្ជកាលព្រះបាទ **ធរណីន្ទ្រវរ្ម័នទី២** ទៅ គឺជារជ្ជកាលរបស់ព្រះបាទ**ជ័យវរ្ម័នទី៧** (គ.ស. ១១៨១-១២១៨)។ ព្រះអង្គ ជាស្ដេចមានព្រះកិត្តិនាមល្បីល្បាញបំផុត នៅក្នុងពង្សាវតារខ្មែរ ហើយព្រះអង្គក៏ជា **មហាពុទ្ធសាសនិកឆ្នើម** គោរពព្រះពោធិសត្វ **លោកេស្វរៈ** និង **ព្រះប្រាជ្ញាបារមិតា** តាមក្រសែព្រះវរបិតា (**ធរណីន្ទ្រវរ្ម័នទី២**)។ នៅក្នុងរជ្ជកាលនេះ គេឃើញមានប្រើពាក្យ "**ពុទ្ធរាជ**" នេះ។ ប្រពៃណីគោរព "ទេវរាជ" ពីបុរាណកាល គឺតាំងពី **ព.ស១៣៤៥** (គ.ស ៨០២) មក ក៏ត្រូវបានជំនួសដោយ "**ពុទ្ធរាជ**" វិញ ព្រោះទ្រង់សព្វរាជហឫទ័យចំពោះ **ទឹកអម្រឹត** នៃសាសនាព្រះចន្ទគឺ **ព្រះសក្យមុនី**។ នៅសម័យនេះ **ពុទ្ធចក្រ** ក្ដី **អាណាចក្រ** ក្ដី សុទ្ធតែចម្រើនរុងរឿង អស្ចារ្យ។ ក្សត្រមួយអង្គៗសុទ្ធតែជា **អង្គទេពតាទាំងអស់** ទោះចូលទីវង្គតទៅហើយ ក្ដី ទោះមានព្រះជន្មនៅ ក្ដី គឺសុទ្ធតែជាអង្គ ព្រះពោធិសត្វ **អវលោកិតេស្វរៈ** ឬ **ព្រះ ប្រាជ្ញាបារមិតា** ដែលប្រកបដោយ **ព្រហ្មវិហារធម៌**[៧]។

ហេតុនេះ ពាក្យ "ពុទ្ធរាជ" នេះមិន មែនជាលទ្ធិផ្សាយមកពីក្រៅ ឬជារបស់ស្ដេចអង្គមុនៗនោះទេ តែជាលទ្ធិដែលកើត ឡើងដោយព្រះបាទជ័យវរ្ម័នទី៧ ដែលបានលើកតម្កើង និងព្រះឋានៈព្រះអង្គទៅជា តួអង្គព្រះពោធិសត្វ

[៥] ប៉ាង ខាត់, ដ.ឯ.ម., ទំព័រ ៦៨

[៦] -ដ-, ទំព័រ ៦៨

[៧] ប៉ាង ខាត់, ដ.ឯ.ម., ទំព័រ ៦៩-៧០

*អរលោកិតេស្វរៈ ហើយដែលគំនិតនេះប្រហែលជាទាញយកលំនាំតាម "លទ្ធិទេវរាជ" របស់ព្រះបាទជ័យវរ្ម័នទី២ ដែលបានលើកតម្លៃ និងព្រះឋានៈព្រះអង្គជាតួអង្គអាទិទេពនៅលើផែនដី។*

## ៣- ខ្លឹមសារ

"*ពុទ្ធរាជ* (king of the Buddha) = "*ពុទ្ធ* (Buddha) + *រាជ* (king)"។

***ពុទ្ធ*** (Buddha) *គឺជា**ភាវឯក*** (unique Being)។ *ព្រះអង្គគឺជា**អ្នកគិតដ៏ជ្រៅបំផុត*** (the profoundest of thinkers), *ជា**វាគ្មិនដ៏ទាក់ទាញ***(the most persuasive of spea-kers), *ជា **អ្នកធ្វើការដ៏មានថាមវន្ត*** (the most energetic of workers), *ជា **អ្នកកែទម្រង់ដ៏ជោគជ័យ*** (the most successful of reformers), *ជា**គ្រូដែលបរិបូរដោយចិត្ត មេត្តានិងសន្តោស*** (the most compas-sionnate and tolerant of teachers), *និងជា**អភិបាលដ៏មានប្រសិទ្ធភាពបំផុត*** (the most efficient of administrators)[8]។ *នៅក្នុងសង្គមពុទ្ធសាសនាខ្មែរ ប្រជាជនខ្មែរ ដែលទទួលយកពុទ្ធសាសនាជាសាសនា ផ្លូវការសម្រាប់ជាតិខ្លួន បញ្ញត្តិ "**ពុទ្ធ**" នេះគឺចង់សំដៅយក**លោកអ្នកត្រាស់ដឹងធម៌ដែលកំបាំង**ដូចយ៉ាង**អរិយសច្ច៤**ជាដើម រហូតដល់ **មគ្គផលនិព្វាន**, ឬ **លោកអ្នកភ្ញាក់រឭក** គឺមានសតិសម្បជញ្ញៈសព្វកាល, ឬលោកអ្នករីកពេញទីដូចជាផ្កាឈូកដែលរីកគ្រប់ស្រទាប់ គឺមានព្រះហឫទ័យរីកដោយអំណាចនៃភាពបរិសុទ្ធ ព្រោះកម្ចាត់កិលេសអស់ហើយ ពោលគឺ ព្រះសម្មាសម្ពុទ្ធ ដែលជាព្រះបរមគ្រូនេះឯង[៩]។*

*ចំណែកឯបញ្ញត្តិ "រាជ* (king)" *ព្រះរាជា (ក្សត្រិយ៍ទ្រង់រាជ្យ); ប្រែតាមរូបសព្ទថា "អ្នករុងរឿងដោយវិសេសព្រោះមានតេជះក្រៃលែង" ឬប្រែថា "អ្នកញ៉ាំងប្រជាពលរដ្ឋឱ្យរីករាយ គឺគ្រប់គ្រងប្រជានិករឱ្យមានស្វាមីភក្តិចំពោះព្រះអង្គ ព្រោះព្រះអង្គមានសង្គហវត្ថុ៤ យ៉ាងគឺ ការឱ្យទេយ្យវត្ថុ, ការពោលវាចាគួរឱ្យចង់ស្ដាប់, ការប្រព្រឹត្តអំពើជាប្រយោជន៍, ការតាំងព្រះអង្គស្មើៗ គឺប្រើឫកពាឱ្យល្មមពេញចិត្តប្រជារាស្ត្រ"។*

*ហេតុនេះបញ្ញត្តិ "**ពុទ្ធរាជ**" មានន័យជារួមថា "**ស្ដេចព្រះពុទ្ធ**"។ "**ស្ដេចព្រះពុទ្ធ**" បើពិចារណាទៅយើងនឹងរកឃើញថា មាន ន័យពីរយ៉ាង។ **ន័យទី១** "**ស្ដេចព្រះពុទ្ធ**" មានន័យថា មានព្រះពុទ្ធមួយអង្គនៅក្នុង ចំណោមព្រះពុទ្ធច្រើនអង្គដែលមាន លក្ខណៈសម្បត្តិលើសពីព្រះពុទ្ធដែលជា ព្រះសម្មាសម្ពុទ្ធបរមគ្រូ ដែលនិកាយថេរវាទគោរពប្រតិបត្តិទៅទៀត។ បើតាមន័យ នេះ ព្រះពុទ្ធមិនមែនមានតែមួយអង្គដែលបានត្រាស់ដឹងនិងបានចូលនិព្វានទៅ ហើយ*

---

[៨] Ven. Narada Mahathera, *The Meaning of life* in Gems of Buddhist Wisdom, 2nd ed., Malaysia, 1996, p 111

[៩] *ជួនណាត, វចនានុក្រមខ្មែរ, រក្សាសិទ្ធិដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ២០០៨, ទំព័រ ពុទ្ធ*

នោះទេ។ រឿងនេះស្របទៅនឹងគំនិតនិកាយមហាយានដែលចូលចិត្តបង្កើតឱ្យមានព្រះពុទ្ធច្រើនអង្គ រាប់រយរាប់ពាន់អង្គ ដោយពួកខាងមហាយានយល់ឃើញថា "*ព្រះពុទ្ធទាំងឡាយជារូបមិនមែនធម្មតា អាស្រ័យនៅដេរដាស គ្រប់ទីកន្លែងក្នុង អាកាស ប្រៀបដូចជា* ***ព្រះពុទ្ធភៃសជ្យគុរុ*** *និង* ***ព្រះ ពុទ្ធអមិតាភ***។ *ឯព្រះពុទ្ធអមិតាភ នេះស្ថិត នៅទិសខាងលិច ក្នុងស្ថានសួគ៌ សុខាវតី*"។ ម្យ៉ាងវិញទៀត ពួកមហាយានយល់ថា "*ព្រះពុទ្ធ១អង្គមានកាយ៣, កាយ ទី១ គឺ* ***ធម៌កាយ*** *(ពោធិ ឬនិព្វាន), កាយ ទី២ គឺ សម្ភោគកាយ (នាមកាយ) កាយទី ៣ គឺ និម្មាណកាយ (កាយជាមនុស្ស)*"[10]។ **ន័យទី២** "**ស្ដេចព្រះពុទ្ធ**" មានន័យថា ព្រះរាជាដែលជាព្រះមហាក្សត្រទ្រង់ជាស្ដេចសោយរាជ្យ ហើយប្រកាន់យកការដឹកនាំ ឬ ការគ្រប់គ្រងប្រទេសរបស់ព្រះអង្គ តាមគោលការណ៍របស់ព្រះពុទ្ធ ឬអាច និយាយបានម្យ៉ាងទៀតថា ជាស្ដេចដែលដើរតួជាព្រះពុទ្ធ ឬក្នុងនាមជាព្រះពុទ្ធ។ នៅត្រង់ចំណុចថា ដើម្បីបានតម្លៃនិងព្រះឋានៈព្រះអង្គជាតួអង្គ **ពុទ្ធរាជ** នៅក្នុងការ គ្រប់គ្រងប្រទេសតើព្រះបាទជ័យវរ្ម័នទី៧ បានប្រារព្ធធ្វើពិធីអភិសេកដូចព្រះបាទ ជ័យវរ្ម័នទី២ដែរឬទេ? ចំពោះរឿងនេះ គេ រកមិនឃើញមានឯកសារនិយាយទេ តែ ទោះជាយ៉ាងណាក៏ដោយក៏ខ្ញុំនៅតែគិតថា ក្នុងព្រះឋានៈព្រះអង្គជាព្រះមហាក្សត្រ ការរៀបចំពិធីគឺត្រូវតែមាន តែគួរឱ្យសោក ស្ដាយដែរដែលមិនមានឯកសារគ្រប់គ្រាន់និយាយពីពិធីនេះ។

## ៤- តាទៈពិសិដ្ឋៗ នៅក្នុងលទ្ធិពុទ្ធរាជ

លទ្ធិពុទ្ធរាជគឺជាលទ្ធិមួយដែលបែកចេញមកពីនិកាយមហាយាន។ លទ្ធិនេះ គោរពបូជាចំពោះព្រះពុទ្ធច្រើនអង្គ ដូចជា ***ព្រះពុទ្ធភៃសជ្យគុរុ*** (Bhaiṣajyaguru), ***ព្រះ ពុទ្ធអមិតាភ...*** និងព្រះពោធិសត្វដូចជា **មញ្ជុស្រី** (Manjushri) គឺជាពោធិសត្វដែល ត្រួតត្រាខាងផ្លូវយុត្តិធម៌ គង់លើរូបសីហហើយកាន់សៀវភៅ១និងព្រះខាន់១។ ***សមន្តភទ្រ*** ជាពោធិសត្វអាណាព្យាបាល អ្នកកាន់សាសនា ដែលគេធ្វើជារូបគង់លើដំរី។ ***មៃត្រេយ*** (Maitreya) គឺព្រះពុទ្ធជា អនាគត ដែលនៅចាំរក្សាសាសនា ដែល ព្រះសមណគោតមបានផ្សាយ។ ***ក្សិតិគភ៌*** គឺពោធិសត្វ ដែលស្រង់មនុស្សពីស្ថាននរក។ ***វជ្របាណិ*** គឺពោធិសត្វដែលមានវជ្រ គឺរន្ទះជាអាវុធក្នុងដៃ ដើម្បីការពារសាសនា[11]។ពោធិសត្វ ***អវលោកិតេស្វរៈ***ឬបទ្មបាណិ ឬលោកេស្វរ, ***ប្រាជ្ញាបារមិតា*** (Prajñāpāramitā)។

_***ព្រះពុទ្ធភៃសជ្យគុរុ*** គឺជា ***ព្រះពុទ្ធព្យាបាល*** (the Buddha of healing) និងជាឱសថ (medicine) នៅក្នុងព្រះពុទ្ធសាសនាមហាយាន។

---

[10] *លី-ហ្វីណូត៍ (ប្រែ ជុំ-ម៉ៅ) "អំពីពុទ្ធសាសនា" បោះពុម្ពលើកទីបី, ភ្នំពេញ, ព.ស២៥០៧, ទំព័រ ១២៨*

[11] *លី-ហ្វីណូត៍, ដ.ឯ.ម., ទំព័រ ១២៨-១២៩*

ជាទូទៅគេហៅព្រះអង្គថាជា "**អរោគ្យពុទ្ធ** (Medicine Buddha)" ដែលជា វេជ្ជបណ្ឌិត(doctor) មួយរូបដែលព្យាបាល ទុក្ខដោយប្រើឱសថ តាមការប្រៀនប្រដៅរបស់ព្រះអង្គ។ នៅសម័យដែលខ្មែរគោរពតាមលទ្ធិពុទ្ធសាសនាមហាយាន មាន**មន្ទីរពេទ្យ** (អរោគ្យសាលា) ចំនួន **១០២** ត្រូវបានកសាងឡើងនៅគ្រប់ខេត្តនៅក្នុង ព្រះរាជាណាចក្រ ហើយនៅតាមមន្ទីរពេទ្យទាំងនេះមាន**ទេវរូបចំនួន៧៩៨** (**ព្រះពុទ្ធភៃសជ្យគុរុ?**)[12]។ មានសិលាចារឹកមួយៗនៅគ្រប់មន្ទីរពេទ្យ។ សិលាចារឹកនេះរៀបរាប់ពីការឧបត្ថម្ភក្នុងមន្ទីរពេទ្យ មានគ្រូពេទ្យ មានគិលានុបដ្ឋាក គិលានុបដ្ឋាយិកា។ល។ ក្រោមអធិបតីភាពព្រះសុគតគឺគ្រូពេទ្យឈ្មោះ "**ភៃសជ្យគុរុ វៃទូរ្យប្រភា**" ហើយនិងបុត្រព្រះជិនស្រី ពីរព្រះអង្គទៀតគឺ **សូរ្យវៃរោចនៈ** និង **ចន្ទ្រវៃរោចនៈ**ហើយជនវណ្ណៈទាំង៤អាចទៅព្យាបាលរោគនៅមន្ទីរពេទ្យបានដូចគ្នា[13]។ ប្រាសាទនាគព័ន្ធបានកសាងឡើងនៅក្នុងរាជ្យរបស់ព្រះបាទជ័យវរ្ម័នទី៧ នៅពាក់កណ្ដាលទី២ នៃសតវត្សទី១២។ ប្រាសាទនេះមានកំពែងក្រៅទំហំ៣៥០ម៉ែត្រ បួនជ្រុងស្មើ។ នៅចំកណ្ដាលស្រះមានប្រាសាទតូចមួយ និងនាគពីរព័ទ្ធពីក្រោម ហើយមានស្រះ៤នៅគ្រប់ទិសទាំង៤។ ស្រះនីមួយៗមានទរសម្រាប់បង្ហូរទឹកលាងបាប ចេញពីស្រះកណ្ដាលដែលជាតួប្រាសាទនាគព័ន្ធ។ ប្រាសាទនាគព័ន្ធនេះជាកំពង់បុណ្យសម្រាប់លាងបាប សាងតំណាងឱ្យស្រះអនោត្ត នៅភ្នំព្រះសុមេរុរាជ (ភ្នំហិមាល័យ) ដែលនិយាយថា មានកំពង់៤ ហូរ ចុះទៅកាន់ទិសទាំង៤ តាមប្រពៃណីប្រទេសឥណ្ឌា ហើយទ្រង់បានសាងបដិមារូបព្រះអង្គទុកជា **អង្គព្រះពុទ្ធគ្រូពេទ្យ** នាម "**ព្រះភៃបជ្យគុរុ វៃទូរ្យប្រភា**" តម្កល់ទុក ក្នុងប្រាសាទនេះផង សម្រាប់ជួយសង្គ្រោះសត្វលោកដែលមានជម្ងឺ[14]។

_**ព្រះពុទ្ធអមិតាភ** (Amitābha) គឺជាព្រះពុទ្ធនៃសេចក្ដីស្រឡាញ់ដ៏ជ្រាលជ្រៅ (the buddha of comprehensive love)។ ព្រះអង្គគង់នៅទិសខាងលិច (តំណាងជា ព្រះពុទ្ធត្រាស់ដឹង ឬសមាធិ) ហើយនិងធ្វើ ការសម្រាប់ការត្រាស់ដឹងនៃសព្វសត្វ ទាំងអស់ (តំណាងជាព្រះពុទ្ធពរ (blessing Buddha)។ ទេពកោសល្យត្រាស់ដឹងដ៏សំខាន់បំផុតរបស់ព្រះអង្គគឺការប្រមើលមើលពិភពលោកជុំវិញជាឋានសួគ៌មួយ។

_**អវលោកិតេស្វរ** (Avalokiteshvara) គឺជាទេវតាវិសេសមួយអង្គ ជាអ្នកពិនិត្យមើលសុខទុក្ខសត្វលោកក្នុងសាសនាព្រះសក្យមុនីគោតម ព្រមទាំង មើលបីបាច់រក្សាសត្វលោកផង។

---

១២ ប៉ាង ខាត់, ជ.ឯ.ម., ទំព័រ ៧៩

១៣ -ដ-, ទំព័រ៩២

១៤ ប៉ាង ខាត់, ជ.ឯ.ម. ទំព័រ ៨១



ព្រះភ័ក្ត្រព្រះពោធិសត្វ ***អវលោកិតេស្វរៈ*** នៅ
លើកំពូលប្រាង្គប្រាសាទបាយ័ន។

*នៅក្នុង សិល្បៈស្ថាបត្យកម្មខ្មែរ គេច្រើនធ្វើមុខ ៤ នៅកំពូលប្រាសាទឬកំពូលចេតិយសម្គាល់ថា ជាព្រះភ័ក្ត្រនៃអវលោកិតេស្វរៈ ដើម្បីការពារ គយន្តរាយទាំងពួងប៉ុន្តែបើហៅតាមលទ្ធិព្រាហ្មណ៍ ថា មុខព្រហ្ម។ គេអាចហៅ* ***អវលោ កេស្វរៈ*** *ក៏បាន ហៅ* ***លោកេស្វរៈ*** (Lokeśvara) *ក៏បាន*[15]*។*



*បដិមាពោធិសត្វព្រះអវលោកេស្វរៈ*

*ចំពោះបដិមាពោធិសត្វអវលោកិតេស្វរៈ ដៃ៤ឬដៃ៨ ក្នុងសិល្បៈចម្លាក់បុរាណ* ***សិល្បៈករខ្មែរ*** *ច្រើនឆ្លាក់រូប* ***ពោធិសត្វ*** *នេះជារូបបុរសវ័យក្មេង មាន****ព្រះហស្ត*** *៤ កាន់* ***ផ្កាឈូក, ខ្សែផ្កាំ, គម្ពីរ*** *និង* ***ដបទឹក*** *។*




*បដិមាព្រះពោធិសត្វ* ***អវលោកិតេស្វរៈ*** *ដៃ៨*
*ប្រភព៖ ក្រសួងអភិរក្សអង្គរ រូបថតស្រាវជ្រាវ ឆ្នាំ*
*២០០៦*

*(សូមកុំច្រឡំនឹង* ***ព្រះវិស្ណុ*** *មាន* ***ព្រះ ហស្ត****៤ ដែរ តែកាន់* ***ផ្កា ឈូក****, កងចក្រ,* ***ក្រទា*** *និង* ***សង្ខ****)* *នៅ លើ* ***ព្រះសិរ*** *របស់ ព្រះអង្គមាន រូប* ***ព្រះពុទ្ធអាមិតាភៈ***[16]*។*

*១៥ ជួនណាត, ដ.ឯ.ម., ទំព័រ អវលោ កិតេស្វរៈ*

*១៦ ត្រឹង ង៉ា, "ប្រវត្តិសាស្ត្រខ្មែរ" ដ.ឯ.ម., ទំព័រ ១០១*

នៅខាងមុខប្រាសាទ**រាជ្យស្រី** ហៅនាគព័ន្ធ មាន**សេះមួយ**កំពុងហោះលឿន ស្ទើរមានចង្កោម មនុស្សតោងកន្ទុយ ជា **បដិមាព្រះ បាទជ័យវរ្ម័ន ទី៧** ដែលមានន័យថា "**ព្រះអង្គដឹកជញ្ជូនសត្វលោកពីមហា សាគរ គឺវាលវដ្តសង្សារត្រែកពទៅ កាន់ ទីក្សេមក្សាន្ត គឺ ព្រះនិព្វាន**"[17]។ សេះនេះ មានឈ្មោះថា**ពលាហក:**។



ប្រាសាទនាគព័ន្ធ ថតនៅខែមករា ឆ្នាំ២០២៤



ព្រះអវលោកេស្វរៈ និមិត្តជា សេះពលាហកៈ
ប្រភព ៖ រូបថតស្រាវជ្រាវឆ្នាំ២០០៦

**ពលាហកៈនេះ**បើតាមលោក**ឈហ្វីណូត៍** និងលោក**វ៉េគោលូបេវ** ថា មានសិលាចារិក នៅ វិមាននាកាសពោលថាព្រះពោធិសត្វ លោកេស្វរៈ តំណែងជា**សេះពលាហកៈ**ហោះទៅស្រោចស្រង់ មហាជនស្រី-ប្រុស ដែលធ្លាយសំពៅលិចលង់ នៅកណ្តាលមហាសមុទ្រ បានទៅជ្រកអាស្រ័យ នៅកោះនាងយក្ខិនីមួយ នាងយក្ខិនីនោះបាន ចាប់ពួកគេបរិភោគជាអាហារបានព្រះពោធិសត្វ **លោកេស្វរៈ** ដែលតំណែងជា សេះ ពលាហកៈ នេះហោះទៅជួយស្រោច ស្រង់មហាជនស្រី ប្រុសនោះមកកាន់ ជម្ពូទ្វីបស្រុកទេសខ្លួនបាន សេចក្តីសុខ។

នៅប្រាសាទ **ជ័យស្រី** ហៅ **ព្រះខាន់** ព្រះបាទជ័យវរ្ម័នទី៧បានកសាងបដិមាព្រះ វររាជបិតាជាតួអង្គ **ពោធិសត្វលោកេស្វរៈ** ថ្វាយព្រះនាមថា "**ជ័យវរមេស្វរៈ**" តម្កល់ទុកក្នុង ប្រាសាទជ័យស្រីនេះ ក្នុងព.ស.១៧៣៤ (គ.ស.១១៩១)[18]។



ប្រាសាទបាយ័នជាការគោរពសកលទេពបូជា (ព្រះពុទ្ធ, ព្រាហ្មណ៍, ព្រះពោធិសត្វ, និងមនុស្ស)

[17] ប៉ាង ខាត់, ដ.ឯ.ម. ទំព័រ៨១-៨២

[18] ប៉ាង ខាត់, ដ.ឯ.ម. ទំព័រ៨២

នៅបច្ចឹមរជ្ជកាលព្រះអង្គ ព្រះបាទជ័យវរ្ម័នទី៧បានសាងប្រាសាទបាយ័នទុកឧទ្ទិសថ្វាយព្រះពុទ្ធសាសនា។ ប្រាសាទ នេះកសាងនៅចំកណ្ដាលមជ្ឈមណ្ឌលនៃព្រះមហានគរ ដើម្បីលើកតម្កើងព្រះកិត្តិ យសតម្កល់ព្រះបដិមាព្រះអង្គ ដែលទុកជា តួអង្គ "ព្រះពុទ្ធរាជ" ហើយនិងពោធិសត្វ **លោកេស្វរៈសមន្តមុខ** នៅគ្រប់កំពូល ប្រូងប្រាង បែរព្រះភក្ត្រញញឹមទៅគ្រប់ ទិសទាំង៤ ក៏ទុកជាតួអង្គព្រះអង្គដែរ។



ព្រះបាទជ័យវរ្ម័នទី៧ ជា"ព្រះពុទ្ធរាជ" ក្នុងនាទីជាពោធិសត្វ **អវលោកិតេស្វរៈ**

ប្រភព ៖ Internet

_**ព្រះប្រាជ្ញាបារមិតា** មានន័យថា ជា "**បារមីគតិបណ្ឌិត** (the Perfection of Wisdom)" ឬជា "**អតិសេដ្ឋពុទ្ធិ** (Transcen-dental Knowledge)" នៅក្នុងពុទ្ធសាសនា មហាយាន។ **ប្រាជ្ញាបារមិតា** សំដៅទៅលើវិធីមើលឃើញធម្មជាតិតថភាព (the nature of reality) ល្អឥតខ្ចោះមួយ ក៏ដូចជាសំ ដៅ ទៅ លើ គួគម្ពីរមហា យាន (សូត្រ) ពិសេសមួយ ដែលពិភាក្សាអំពីគតិបណ្ឌិត នេះផងដែរ។

**ប្រាជ្ញាបារមិតា** ក៏អាចសំដៅទៅលើទេពធីតា គឺ **ប្រាជ្ញាបារមិតាទេវី** (Prajñāpā-ramitā Devi) **ដែល**ជាបដិរូបកម្មបារមីគតិបណ្ឌិត (personification of the perfection wisdom) ឬក៏គេអាចស្គាល់ថាជា "មហាមាតា(Great Mother)" ក៏បាន។

នៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់បានកសាងប្រាសាទតាព្រហ្ម រួចហើយឱ្យឈ្មោះថា "ព្រះរាជវិហារ" ពី ព. ស.១៧២៩ (គ.ស. ១១៨៦) ដើម្បីឧទ្ទិសថ្វាយព្រះពុទ្ធសាសនាផង និងដើម្បីតម្កល់បដិមាព្រះនាង **ជ័យរាជចូឌាមណី** ដែលជាព្រះវររាជមាតា ទុកជា **អង្គព្រះប្រាជ្ញា បារមិតា** គឺជាមាតាបង្កើតព្រះពុទ្ធ[19]។

សរុបសេចក្ដីមក លទ្ធិពុទ្ធរាជរបស់ព្រះបាទជ័យវរ្ម័នទី៧ ដែលព្រះអង្គសម្ដែងតួជាព្រះពោធិសត្វ **លោកេស្វរៈ** បានប្រែក្លាយព្រះរាជាណាចក្ររបស់ព្រះអង្គទៅ ជាឋានសួគ៌ ឬឋានទេវលោក ហើយ ក្សត្រាក្សត្រីមួយអង្គៗ សុទ្ធតែជា **តួអង្គទេពតា**, តួអង្គព្រះពោធិសត្វ អវលោកិតេស្វរៈ ឬព្រះប្រាជ្ញាបារមិតា ដែល

[19] ប៉ាង ខាត់, ដ.ឯ.ម. ទំព័រ ៧១

*ប្រកប ដោយ **ព្រហ្មវិហារធម៌**។ ទាំងអស់នេះរត់ស្របទៅតាមព្រះរាជទស្សនៈ ដែលជា ព្រះរាជបំណងរបស់ព្រះអង្គថា "កសាងប្រទេសកម្ពុជាឱ្យក្លាយទៅជាឋានសួគ៌ ហើយកសាងប្រជាជនខ្មែរឱ្យទៅជាទេវតា ប្រាកដមែនទ។*

## ៥- គោលបំណងនៃលទ្ធិពុទ្ធរាជ

*លទ្ធិពុទ្ធរាជគឺជាមែកធាងមួយនៃព្រះពុទ្ធសាសនាមហាយាន។ ព្រះពុទ្ធសាសនាមហាយានគឺជាយានធំទូលាយ មួយដែលអាចផ្ទុកសត្វលោកបានច្រើនគ្នាទៅកាន់គោលដៅត្រឹម **ពោធិសត្វ**[20] ដែលមាន **ពោធិញាណ**[21] ជាទីបំផុត ដែលខុសពីនិកាយ**ថេរវាទ** ដែលមានគោលដៅប្រាថ្នាយក **ព្រះអរហត្ត** និង **ព្រះនិព្វាន**[22] ជាទីបំផុត។*

*នៅក្នុងនិកាយមហាយានមានពាក្យគន្លឹះមួយចំនួនដែលជួយឱ្យយើងយល់ និកាយពុទ្ធសាសនាមហាយាន ក៏ដូចជា លទ្ធិពុទ្ធរាជ បានស៊ីជម្រៅ ពាក្យទាំងនោះមានដូចខាងក្រោមៈ*

▶ ***ពោធិ*** (bodhi) *គឺជា ការត្រាស់ដឹង លោកុត្តរធម៌, គឺជាប្រាជ្ញាដែលព្រះសព្វញ្ញុពុទ្ធទ្រង់បានត្រាស់*[23]*។ **ពោធិ** គឺជាពាក្យបាលីសំស្រ្កឹតសម្រាប់ "**ការត្រាស់ដឹង*** (enlightenment)*"។ ពាក្យនេះសំដៅ ចំពោះ **គោលដៅជួយសង្គ្រោះ*** (soterio-logical goal) *របស់ព្រះពុទ្ធសាសនា ដែលជាការសម្រេចបាននូវ **ការត្រាស់ដឹង**។ ពាក្យថា"ពុទ្ធ" ខ្លួនឯង មានន័យថា អ្នក ដែលបានសំរេច "**ពោធិ**" ("ការរលឹកដឹង ខ្លួន")។ បើទោះជាគេប្រើជាទូទៅនៅក្នុង បរិបទព្រះពុទ្ធសាសនាក៏ដោយ ក៏ពាក្យ **ពោធិ** នេះគឺជាពាក្យបច្ចេកទេសមួយដែល មានការប្រើប្រាស់ផ្សេងៗគ្នានៅក្នុងទស្សនវិជ្ជានិងប្រពៃណីឥណ្ឌាដែរ។*

▶ ***ពោធិសត្វ*** (bodhisattva) *ឬជា ភាសាបាលីថា **ពោធិសត្ត*** (bodhisatta) *បើនៅ ក្នុងពុទ្ធសាសនាដើម ឬពុទ្ធសាសនា ថេរវាទ ពាក្យនេះសំដៅចំពោះអ្នកដែលមានចិត្តឬមានសេចក្តីប្រាថ្នាជាប់នៅក្នុងពោធិ គឺអ្នកដែលកំពុងខំប្រឹងបំពេញបារមី បម្រុងនឹងបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ; បើទុកជាក្លាត់ជាតិទៅកើតជាតិរច្ឆាន ក៏គង់នៅហៅថា ព្រះពោធិសត្វ ដែរ ព្រោះមានបំណងនោះជាប់នៅមិនបាត់*[24]*។ បើនៅក្នុង ព្រះពុទ្ធសាសនាមហាយានវិញ ពាក្យ **ពោធិសត្វ** សំដៅចំពោះអ្នកដែលបង្កើត **ពោធិចិត្ត*** (bodhicitta) *ដែលជា **សេចក្តី ប្រាថ្នាសយម្ភូត*** (spontaneous wish) *និង **មេត្តាចិត្ត*** (compassionate mind) *ដើម្បី បានទៅដល់ **ព្រះពុទ្ធភាព*** (Buddhahood) *ដែលជាប្រយោជន៍ដល់សព្វសត្វទាំងឡាយ* (all sentient beings)*។ ព្រះ*

[២០] *ត្រឹង ង៉ា "អរិយធម៌ខ្មែរ" ភ្នំពេញ ?, បោះពុម្ពលើកទី៣, ១៩៧៤, ទំព័រ ៥០*

[២១] *លី-ហ្វីណូត៍, ដ.ឯ.ម., ទំព័រ ១២៧*

[២២] *-ដ-, ទំព័រ ១២៧*

[២៣] *ជួនណាត, ដ.ឯ.ម., ទំព័រ ពោធិ*

[២៤] *ជួនណាត, ដ.ឯ.ម., ទំព័រ ពោធិសត្វ*

ពោធិសត្វមហាយានគឺជាមនុស្សមានចិត្តស្វាហាប់ ដែលធ្វើការដើម្បីបានដល់ **ការរលឹកដឹងខ្លួន** ហើយត្រូវបានជំរុញដោយ **មហាករុណា** (great compassion)។ ភាវៈទាំងនេះត្រូវបានលើកជាគំរូដោយគុណសម្បត្តិ ផ្លូវចិត្តសំខាន់ៗដូចជា "**ចតុទេវឋាន** (four divine abodes) ដែលជា **ព្រហ្មហារធម៌** (brahmavihāras)"មាន **មេត្រី** (loving-kindness), **ករុណា** (compassion), **មុទិតា** (empathetic joy), និង **ឧបេក្ខា** (equanimity) ក៏ដូចជា"**បារមី** (perfections) ឬ **បារមិតា** (Pāramitās) ព្រះពោធិសត្វផ្សេងៗទៀតដែរ ដោយ គិតរួមទាំង **ប្រាជ្ញាបារមិតា** (prajñāpāramitā) ដែលជា **អតិសេដ្ឋពុទ្ធិ** (transcendent knowledge) ឬ"**គតិបណ្ឌិត បារមី** (perfection of wisdom)"ផង។

គោលបំណងរបស់ពួកមហាយានដែលប្រាថ្នាយកត្រឹម **ព្រះពោធិសាត្វ** នោះ គឺដើម្បីនៅចាំជួយណែនាំប្រោសសត្វលោក[25]។ រឿងនេះអាចបញ្ជាក់បានពីគោលបំណងរបស់ព្រះបាទជ័យវរ្ម័នទី៧ ដែលទ្រង់ចង់គង់នៅជាព្រះពោធិសត្វ ក្នុងនាមជា **ព្រះពោធិសត្វលោកិតេស្វរៈ** ដើម្បីចាំជួយស្រោចស្រង់អ្នកដែលមានទុក្ខឱ្យផុតទុក្ខ។ បដិមា **សេះពលាហកៈ** ដែលមានចង្កោមមនុស្សតោងនៅខាងកើតប្រាសាទនាគព័ន្ធគឺជាបដិមាតំណាងឱ្យព្រះបាទជ័យវរ្ម័នទី៧ ដែលដើរតួជាព្រះពោធិសត្វលោកេស្វរៈតំណែងធ្វើជាសត្វសេះ **ពលាហកៈ**

[25] ត្រឹង ង៉ា "អរិយធម៌ខ្មែរ" ដ.ឯ.ម.ទំព័រ ៥០

ដើម្បីជួយស្រោចស្រង់អ្នក ដែលចង់ឱ្យព្រះអង្គជួយ។ សិលាចារឹក នៅប្រាសាទ **តាព្រហ្ម** ដែលជាស្នាព្រះហស្តព្រះរាជបុត្រព្រះអង្គព្រះនាម **សូរ្យកុមារ** ទ្រង់តែងឡើងពីបំណងរបស់ព្រះបិតាព្រះអង្គថា "ព្រះពុទ្ធដ៏មានបុណ្យអង្គ ណាមានកាយចែកជា៣ចំណែក គឺ ធម៌ កាយ១ សម្ភោគកាយ ១ និម៌ានកាយ១ ដែលជាផលកើតចេញមកពីសម្ភារគឺ បុណ្យ យើងខ្ញុំនមស្ការចំពោះអង្គព្រះពុទ្ធ នោះ ដែលជាចំណែកនៃរាងកាយព្រះជិន ស្រីនិងបុត្រនៃព្រះជិនស្រី ហើយកើត បានជាសរណៈនៃសត្វលោក"[26]

▶ **ពោធិញាណ** (bodhiñāṇa) ប្រាជ្ញាជាគ្រឿងត្រាស់ដឹង : ព្រះសិទ្ធត្ថគោតមទ្រង់បានសម្រេចពោធិញាណ[27]។

និកាយមហាយាននិយម **ធម៌ថ្មី** គឺ **ធម៌ដែលមានវិន័យធូរស្រាល** ហើយគោរពប្រតិបត្តិតាម **លទ្ធិអាចរិយវាទ** ពោលគឺ តាមគ្រូអាចារ្យរបស់ខ្លួនតៗគ្នា ពុំមែនគោរពតាម **ពុទ្ធោវាទ** ដូចនិកាយ ថេរវាទនោះទេ។ ដូចនេះ និកាយមហាយាន ពុំគោរព **ព្រះពុទ្ធ** ជាធំទេ[28]។

សរុបសេចក្តីមក គោលគំនិតនៃ និកាយមហាយាន ក៏ដូចជាគោលគំនិតនៃ **លទ្ធិពុទ្ធរាជ** របស់ព្រះបាទជ័យវរ្ម័នទី៧ដែរ ការចង់មានជីវិតរស់នៅជាព្រះពោធិសត្វ គឺដើម្បីងាយស្រួល

[26] ប៉ាង ខាត់, ដ.ឯ.ម. ទំព័រ ៧១-៧២

[27] ជួនណាត, ដ.ឯ.ម., ទំព័រ ពោធិ

[28] ត្រឹង ង៉ា "អរិយធម៌ខ្មែរ" ដ.ឯ.ម.ទំព័រ ៥០

*ផ្សាយកុសលរបស់ខ្លួន ដល់អ្នកដទៃទៀត នៅក្នុងន័យថា ចាំជួយសង្គ្រោះអ្នកដទៃឱ្យរួចផុតពីទុក្ខ។*

## សេចក្ដីសន្និដ្ឋាន

*លទ្ធិទេវរាជ របស់ព្រះបាទជ័យវរ្ម័នទី២ ដែលបានលើកតម្លៃនិងព្រះឋានៈ ព្រះអង្គជាតួអង្គអាទិទេពនៅលើផែនដី បានធ្វើឱ្យប្រទេសខ្មែរមានឥស្សរភាពពីការឈ្នានពាន់របស់ជ្វា រួចហើយលទ្ធិនេះបានធ្វើឱ្យប្រជាជនខ្មែរមានការរួបរួមគ្នា ក្រោមការដឹកនាំរបស់ស្ដេចអាទិទេព ពោលគឺ ព្រះបាទជ័យវរ្ម័នទី២ បានធ្វើឱ្យប្រទេសនិងអរិយធម៌ប្រទេសនេះមានការរីកចម្រើនគ្រប់ប្រការជាលំដាប់។*

*តាមគំរូដ៏ឆ្លាតវៃនេះ ព្រះបាទជ័យវរ្ម័នទី៧ បានលើកយកលទ្ធិថ្មីផ្សេងមួយ ផ្ទាល់របស់ព្រះអង្គ ពោលគឺ "**លទ្ធិពុទ្ធរាជ**" មកប្រើនៅក្នុងនយោបាយដឹកនាំ ប្រទេស ដោយលើកព្រះអង្គឯងទៅជាស្ដេចព្រះពុទ្ធ ហើយដើរតួជា **ព្រះពោធិសត្វអវលោកិតេស្វរៈ** ដើម្បីចាំជួយស្រោចស្រង់ប្រជារាស្ត្រព្រះអង្គ ដែលមានទុក្ខ ហើយដែលត្រូវការឱ្យព្រះអង្គជួយ។ គំនិតនេះ ព្រះវីរកុមារ ព្រះរាជបុត្រាព្រះអង្គបានចារទុកនៅក្នុងសិលាចារឹក ប្រាសាទព្រះខាន់ថា "ទ្រង់ខ្លោចផ្សាក្រៃ លែងចំពោះពេគនៃជនអ្នកមានរោគកាយ (ប្រជាជនព្រះអង្គ) ជាងព្រះអាពាធផ្ទាល់ ព្រះអង្គ ព្រោះថា ទុក្ខរាស្ត្រជាទុក្ខនៃអ្នកគ្រប់គ្រង (គឺព្រះអង្គ) ទាំងឡាយពុំមែន ចំពោះទុក្ខផ្ទាល់ព្រះវរកាយព្រះអង្គ ឡើយ។១៣។*

*គំនិតខាងលើនេះបានធ្វើឱ្យរជ្ជកាលព្រះអង្គក្លាយជារជ្ជកាលនៃព្រះពោធិសត្វ ដែលគ្រប់កំពូលប្រាង្គប្រាសាទនៅក្នុង សុទ្ធសឹងតែលោកកេស្វរៈសមន្តមុខ ព្រះ នេត្របិទពាក់កណ្ដាល សម្លឹងចុះក្រោម ព្រះភក្ត្រញញឹមដោយសេចក្ដីសង្ឃឹម និង សេចក្ដីស្ងប់ហៅថា "ញញឹមបាយ័ន"។ ព្រះអង្គបានកសាងប្រាសាទបន្ទាយក្ដី, ប្រាសាទតាព្រហ្ម, ព្រះ ខាន់, បាយ័ន, មន្ទីរពេទ្យ។ ក្រៅពីព្រះរាជធានីនៅមហានគរ ទ្រង់កសាងប្រាសាទ វត្តនគរ (កំពង់ចាម), តាព្រហ្ម (ទន្លេបាទី តាកែវ), ប្រាសាទមួយ នៅបន្ទាយឆ្មារ និង ទីឋានដទៃទៀតច្រើន អនេក ដើម្បីឱ្យសមតាមព្រះរាជបំណងថា "កសាងប្រទេសកម្ពុជាឱ្យក្លាយទៅជាឋាន សួគ៌ និងកសាងប្រជាជនខ្មែរឱ្យទៅជាទេវតា)"។*

*លទ្ធិពុទ្ធរាជមានទំនោរខុសពីទំនោរនៃលទ្ធិទេវរាជ ដែលបាញ់ ឆ្ពោះទៅរកកម្លាំងអាទិទេព។ ឯលទ្ធិពុទ្ធរាជមានទំនោរទៅរកតម្លៃ, គុណសម្បត្តិ, និងសមត្ថភាពរបស់**មនុស្ស**។ ថ្វីត្បិតតែលទ្ធិទាំងពីរមានទំនោរ ខុសគ្នាតែលទ្ធិទាំងពីរនេះមានគោល បំណងរួមគ្នាមួយគឺ បម្រើសំដៅលើកស្ទួយ និងអភិវឌ្ឍប្រទេសជាតិ និងជីវភាពប្រជារាស្ត្រខ្មែរឱ្យចម្រើនរុងរឿង ទាំងខាងផ្លូវកាយ និងទាំងខាងផ្លូវចិត្ត។ ព្រះបាទជ័យវរ្ម័នទី២គឺជាគំរូល្អជះឥទ្ធិពលដល់ព្រះបាទជ័យវរ្ម័នទី៧ ហើយក៏ជាវិភាគទានដ៏*

ប្រពៃ សម្រាប់អ្នកដឹកនាំជំនាន់ក្រោយៗ ដែលត្រូវរៀនសូត្រតៗគ្នាពីជំនាន់មួយទៅជំនាន់មួយៗ អ្នកដឹកនាំដែលចេះរៀនសូត្របទពិសោធន៍ល្អពីអ្នកមុនៗនឹងមិនដើរជាន់ដានប្រវត្តិសាស្ត្រដដែលៗ

## គន្ថនិទ្ទេស


១- ជួនណាត, *វចនានុក្រមខ្មែរ,* រក្សាសិទ្ធិ ដោយវិទ្យា ស្ថានពុទ្ធសាសនបណ្ឌិត្យ, ២០០៨

២- ប៉ាង ខាត់, ប្រវត្តិពុទ្ធសាសនានៅ ប្រទេសខ្មែរនៅក្នុង "*ពុទ្ធសាសនា ២៥០០*", ភ្នំពេញ, ព.ស. ២៥២៥ (គ.ស.១៩៥៧), ការផ្សាយរបស់ វិទ្យាស្ថាន ពុទ្ធសាសនបណ្ឌិត្យ គ.ស. ២០០១

៣- ត្រឹង ង៉ា, *ប្រវត្តិសាស្ត្រខ្មែរ ភាគ១ និង ភាគ២* (សម្រាប់មធ្យមសិក្សានិង ឧត្តមសិក្សា)" ភ្នំពេញ, ព.ស.២៥១៧ គ.ស.១៩៧៣

៤- ត្រឹង ង៉ា "អរិយធម៌ខ្មែរ" ភ្នំពេញ ?, បោះពុម្ពលើកទី៣, ១៩៧៤

៥- លី-ហ្វីណូត៍ (ប្រែ ជុំ-ម៉ៅ) "*អំពីពុទ្ធ សាសនា*" បោះពុម្ពលើកទីបី, ភ្នំពេញ, ព.ស២៥០៧

- Ven. Narada Mahathera, *The Meaning of life* in Gems of Buddhist Wisdom, 2nd ed., Malaysia, 1996